អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## ចក្រភពអង់គ្លេសផ្តល់ជំនួយថវិកាចំនួន ២១៥ ០០០ ផោន ដល់ខាងភាគីកម្ពុជានៃ អ.វ.ត.ក.

រាជរដ្ឋាភិបាលនៃចក្រភពអង់គ្លេសបានអះអាងបញ្ជាក់អំពីការផ្តល់ជំនួយថវិកាចំនួន ២១៥ ០០០ ផោន (ស្មើនឹងប្រមាណ ៣៣៤ ០០០ ដុល្លារសហរដ្ឋអាមេរិក) ដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ដើម្បីបំពេញតម្រូវការខាងភាគីកម្ពុជា ក្នុងចន្លោះរយៈពេលរង់ចាំការមកដល់នៃជំនួយមកពីប្រទេសផ្តល់ជំនួយផ្សេងៗទៀត។

នៅក្នុងលិខិតផ្ញើរជូនឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. លោកឯកអគ្គរាជទូត អេនឌ្រូ ម៉េស បានជម្រាបជូនថា រាជរដ្ឋាភិបាលអង់គ្លេសមានឆន្ទៈខ្ពស់ក្នុងការគាំទ្រកិច្ចការរបស់ អ.វ.ត.ក. ក្នុងខណៈដែលតុលាការនេះកំពុងតែបោះជំហានទៅរកដំណាក់កាលដ៏សំខាន់មួយទៀតនៃអាណត្តិការងាររបស់ខ្លួន។

ចក្រភពអង់គ្លេសស្ថិតក្នុងចំណោមប្រទេសម្ចាស់ជំនួយសំខាន់ៗដែលបានផ្តល់ការគាំទ្រចំពោះ អ.វ.ត.ក. តាំងពីតុលាការនេះបង្កើតឡើងនៅឆ្នាំ២០០៦។ មកដល់បច្ចុប្បន្ននេះ ថវិកាដែល អ.វ.ត.ក. បានទទួលពីចក្រភពអង់គ្លេសគឺមានចំនួន ៣,៧ លានដុល្លារសហរដ្ឋអាមេរិក។

នៅក្នុងលិខិតឆ្លើយតប ឯកឧត្តម ក្រាញ់ តូនី បានសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះចក្រភពអង់គ្លេស និងជាពិសេសស្ថានទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបន្តផ្តល់ការគាំទ្ររបស់ខ្លួនចំពោះ អ.វ.ត.ក.។

ព័ត៌មានបន្ថែម សូមទាក់ទង៖


**រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ៖ +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក៖ reach.sambath@eccc.gov.kh

**ឌឹម សុវណ្ណារ៉ុំ**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥-១២ ៤៨៨ ០៩៤
ទូរសារ៖ +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក៖ dim.sovannarom@eccc.gov.kh